ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


ក្រសួងផែនការ

អគ្គនាយកដ្ឋានផែនការ

នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ


# វឌ្ឍនភាពនៃកិច្ចដំណើរការរៀបចំ យន្តការ និងនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍

ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២


ដោយឯកឧត្តម កែវ អ៊ូលី

# មាតិកា

១. សេចក្តីផ្តើម

២. វឌ្ឍនភាពនៃការរៀបចំនីតិវិធី

៣. សេចក្តីសង្ខេបនៃជំហានអនុវត្ត

៣.១. ការបណ្តុះបណ្តាល

៣.២. ដំណើរការផ្តល់បណ្ណសមធម៌ និង ដំណើរការដកបណ្ណសមធម៌ពីអ្នកផ្ទុកមេរោគអេដស៍

៣.៣. ការតាមដានត្រួតពិនិត្យ និងការគ្រប់គ្រងមតិជំទាស់និងសំណូមពរ

៣.៤. រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច

ក្រសួងផែនការ → អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ → មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ → អ្នកមានចំណែកពាក់ព័ន្ធដទៃទៀត

៣.៥. ការរក្សាការសំងាត់នៃទិន្នន័យអ្នកផ្ទុកមេរោគអេដស៍

៤. ជំហានបន្ទាប់

# ១. សេចក្តីផ្តើម (១)

- ឆ្នាំ២០០៧ បានធ្វើការសាកល្បងអត្តសញ្ញាណកម្មក្រីក្រនៅទីជនបទ
- ឆ្នាំ ២០០៨ បានអនុវត្តអត្តសញ្ញាណគ្រួសារក្រីក្រនៅទីជបបទក្នុង ៨-៩ រាជធានី ខេត្ត(ស្រុកប្រតិបត្តិសុខាភិបាល)
- ឆ្នាំ២០០៩-២០១៣ អត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានគ្របដណ្តប់លើភូមិទីជនបទទាំងអស់នៅទូទាំងប្រទេស
- ឆ្នាំ២០១៦ បានរៀបចំ និងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅទីប្រជុំជន
- ឆ្នាំ២០១៩ បានគ្របដណ្តប់ស្របពេលជាមួយគ្នារវាងភូមិនៅទីជនបទ និងភូមិនៅទីប្រជុំជន និងប្រើប្រាស់ទម្រង់បែបបទជាក្រដាសស្នាមសម្រាប់ធ្វើបច្ចុប្បន្នកម្មទិន្នន័យរៀងរាល់បីឆ្នាំ
- រយៈពេលបីឆ្នាំនៃការធ្វើបច្ចុប្បន្នភាពទិន្នន័យគ្រួសារក្រីក្រមានន័យថា
  - ✓ គ្រួសារដែលខកខានមិនបានធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
  - ✓ ការធ្វើចំណាកស្រុក ឬ
  - ✓ ដោយហេតុថាធ្លាក់ចូលក្នុងភាពក្រីក្រ ឬ
  - ✓ ចាកផុតពីភាពក្រីក្រ

# ១. សេចក្តីផ្តើម (២)

- ចុងឆ្នាំ២០១៧ បានអនុវត្តសាកល្បងយន្តការប្រើប្រាស់ទម្រង់បែបបទជាឌីជីថល ហៅថា **អត្តសញ្ញាណកម្មគ្រួសារក្រីក្រ តាមការស្នើសុំរបស់គ្រួសារដែលមានការលំបាកផ្នែកជីវភាព**
- ឆ្នាំ២០២០ ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ក្នុងកំឡុងពេលនៃការរីករាលដាលជំងឺកូវីដ១៩ បានផ្តល់ទិន្នន័យគ្រួសារក្រីក្រជូនដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លើយតបក្នុងការផ្តល់អន្តរាគមន៍ជំនួយសង្គមជាបន្ទាន់ដល់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះ
- ឆ្នាំ២០២០ ក្រសួងផែនការបានសម្រេចធ្វើការកែសម្រួលនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ពីធ្វើបច្ចុប្បន្នកម្មទិន្នន័យរៀងរាល់៣ឆ្នាំ(ដោយគ្របដណ្តប់លើគោលដៅ ៨-៩រាជធានី ខេត្ត រៀងរាល់ឆ្នាំ) **មកធ្វើបច្ចុប្បន្នកម្មទិន្នន័យប្រចាំឆ្នាំវិញ (ដោយគ្របដណ្តប់លើគោលដៅទាំង២៥រាជធានី ខេត្ត រៀងរាល់ឆ្នាំ)** ដោយមានការគាំទ្រពីអង្គការជីអាយហ្សិត(GIZ) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) និង ធនាគារពិភពលោក(WB) គឺ នីតិវិធីកែសម្រួលថ្មីនេះ បានកែសម្រួល (១)បញ្ជីសំណួរ និង(២)ប្រព័ន្ធដាក់ពិន្ទុតាមការចំណាយលើការប្រើប្រាស់សរុបសម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ
- អនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ→ **មានភារកិច្ចដឹកនាំ និងគ្រប់គ្រងការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជនងាយរងគ្រោះ**

# ១. សេចក្ដីផ្ដើម (៣)

- ផែនការយុទ្ធសាស្ត្រថវិកា២០២៣-២០២៥ បានដាក់ចេញនូវការផ្ដល់ជំនួយគាំទ្រដល់គ្រួសារដែលរស់នៅកៀកនឹងបន្ទាត់ភាពក្រីក្រ
- ឆ្នាំ២០២២ ក្រសួងផែនការ បានសហការជាមួយដៃគូអភិវឌ្ឍន៍(GIZ, UNDP, WB) បានរៀបចំឱ្យមានសេចក្ដីណែនាំអំពីយន្តការ និងនីតិវិធីអត្តសញ្ញាណកម្មគ្រួសារងាយរងហានិភ័យ
- ឆ្នាំ២០២១-២០២២ ក្រសួងផែនការ បានរៀបចំឱ្យមានសេចក្ដីណែនាំស្ដីពីនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ ដោយមានការចូលរួមសហការពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគនៃក្រសួងសុខាភិបាល និង ដៃគូអភិវឌ្ឍន៍(រួមមាន GIZ UNDP/UNAIDS)

  → សេចក្ដីជូនដំណឹងលេខ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩៖
  - ✓ បានឯកភាពជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដាក់ចេញវិធានការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍
  - ✓ បានចង្អុលបង្ហាញដល់ក្រសួងស្ថាប័នពាក់ព័ន្ធឱ្យអនុម័តវិធានការបញ្ចូលការឆ្លើយតបនឹងមេរោគអេដស៍
  - ✓ ក្រសួងផែនការ និងក្រសួងសុខាភិបាលរួមគ្នាដើម្បីកំណត់អ្នកផ្ទុកមេរោគអេដស៍ជាក្រុមប្រជាជនងាយរងគ្រោះដែលត្រូវទទួលបានបណ្ណសមធម៌ដើម្បីធានាដល់ការទទួលបានសេវាថែទាំសុខភាព និងការគាំពារសង្គម

# ២. វឌ្ឍនភាពនៃការរៀបចំនីតិវិធី

- បានរៀបចំក្រុមការងារ និងកៀរគរធនធានសម្រាប់ការរៀបចំ APP និងសេចក្តីណែនាំ ស្តីពីនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
- ដោយមានការជួយគាំទ្រពីUNDP/UNAIDS បានរៀបចំ APP សម្រាប់ការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ ដោយមានការពិគ្រោះយោបល់ពីអ្នកពាក់ព័ន្ធ
- ដោយមានការជួយគាំទ្រពី GIZ បានរៀបចំពង្រាងសេចក្តីណែនាំស្តីពីនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ដោយមានការពិគ្រោះយោបល់ពីអ្នកពាក់ព័ន្ធ

# ៣.១. ការបណ្តុះបណ្តាល

- ក្រុមការងារនាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវសហការ និងសម្របសម្រួលជាមួយអ្នកមានចំណែកពាក់ព័ន្ធរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីបង្គោលទទួលបន្ទុកការងារចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ពាក់ព័ន្ធទាំងអស់
- មន្ត្រីបង្គោលទទួលបន្ទុកការងារចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍នៅតាមគ្លីនីកART ត្រូវធ្វើការងារនេះ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាល

# ៣.២. ដំណើរការផ្តល់បណ្ណសមធម៌ និង ដំណើរការដកបណ្ណសមធម៌ (១)

- កិច្ចដំណើរការផ្តល់បណ្ណសមធម៌ជូនអ្នកផ្ទុកមេរោគអេដស៍ ត្រូវអនុវត្តជាប្រចាំដោយមន្ត្រីបង្គោលទទួលបន្ទុកចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ ដោយមានការជួយគាំទ្រពីអ្នកមានចំណែកពាក់ព័ន្ធដទៃទៀត។
- ដំណើរការអនុវត្តនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍រួមមាន (១)ដំណើរការផ្តល់បណ្ណសមធម៌ (២)ដំណើរការដកបណ្ណសមធម៌
- ដំណើរការផ្តល់បណ្ណសមធម៌ ត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

| ជំហាន ១ | ជំហាន ២ | ជំហាន ៣ | ជំហាន ៤ | ជំហាន ៥ |
|---|---|---|---|---|
| ការពិនិត្យបណ្ណសមធម៌របស់អតិថិជន | ការបំពេញពាក្យយល់ព្រមផ្តល់សម្ភាសន៍ | ការសម្ភាសន៍ | ការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ និង ការអនុម័ត | ការបោះពុម្ព និងការផ្តល់បណ្ណសមធម៌ |
| អ្នកសម្ភាសន៍ | អ្នកសម្ភាសន៍ | អ្នកសម្ភាសន៍ | មន្ត្រីផ្ទៀងផ្ទាត់ មន្ត្រីអនុម័ត | មន្ត្រីផ្ទៀងផ្ទាត់ មន្ត្រីអនុម័ត |

# ជំហានទី១៖ ការពិនិត្យបណ្ណសមធម៌របស់អតិថិជន

- ❑ អតិថិជនទៅរកសេវាសុខភាពនៅតាមគ្លីនិកART តាមការណាត់របស់គ្រូពេទ្យ
- ❑ អ្នកសម្ភាសន៍ ត្រូវសាកសួរព័ត៌មានដើម្បីទទួលបានព័ត៌មានថាតើ **មាន/គ្មាន**បណ្ណសមធម៌?

**មាន**បណ្ណសមធម៌នៅមានសុពលភាព៖

- ✓ ផ្ទៀងផ្ទាត់ព័ត៌មានស្ថានភាពផ្ទុកមេរោគអេដស៍ក្នុងមូលដ្ឋានទិន្នន័យក្រសួងផែនការ
- ✓ ធ្វើបច្ចុប្បន្នកម្មព័ត៌មាននៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកផ្ទុកមេរោគអេដស៍
- ✓ ធ្វើបច្ចុប្បន្នកម្មទិន្នន័យអ្នកផ្ទុកមេរោគអេដស៍

**គ្មាន**បណ្ណសមធម៌៖

- ✓ ត្រូវផ្តល់ការណែនាំអំពីអត្ថប្រយោជន៍នៃបណ្ណសមធម៌
- ✓ លក្ខខណ្ឌចូលរួមដោយស្ម័គ្រចិត្ត៖
  - ➢ ត្រូវបំពេញពាក្យយល់ព្រមផ្តល់សម្ភាសន៍
  - ➢ ផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណ
- ✓ ត្រូវសួរបញ្ជាក់អតិថិជន ថាតើចង់បានបណ្ណសមធម៌ដែរឬទេ?
  - ➢ មិនចង់បាន៖ កត់ត្រាមតិយោបល់ (បើមាន) និងបិទបញ្ចប់នីតិវិធី
  - ➢ ចង់បាន៖ ត្រូវបន្តនីតិវិធី(បន្តជំហានទី២)

# ជំហានទី២៖ ការបំពេញពាក្យយល់ព្រមផ្តល់សម្ភាសន៍

- អតិថិជន ត្រូវបំពេញពាក្យយល់ព្រមផ្តល់សម្ភាសន៍ រួចចុះហត្ថលេខា ឬផ្តិតមេដៃស្តាំ
- អ្នកសម្ភាសន៍ត្រូវធានាថាអតិថិជន បានយល់ពីការរក្សាទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ជាការសំងាត់បំផុត
- អ្នកសម្ភាសន៍ ត្រូវរក្សាទុកពាក្យយល់ព្រមផ្តល់សម្ភាសន៍ក្នុងទូរឯកសារដែលមានសោរចាក់យ៉ាងត្រឹមត្រូវ។

# ជំហានទី៣៖ ការសម្ភាសន៍

- អ្នកសម្ភាសន៍ ត្រូវប្រើប្រាស់គណនីចូលទៅមុខងារ**អ្នកសម្ភាសន៍** សម្រាប់បំពេញព័ត៌មានដែលទទួលបាន
- អ្នកសម្ភាសន៍ ត្រូវបង្កើតករណីដោយបំពេញព័ត៌មានអតិថិជនដែលបានបំពេញពាក្យយល់ព្រមផ្តល់សម្ភាសន៍
- អ្នកសម្ភាសន៍ ត្រូវពិនិត្យករណីដែលខ្លួនបានបង្កើតរួចនូវព័ត៌មានអំពីអត្តសញ្ញាណបុគ្គលផ្តល់សម្ភាសន៍ និងធ្វើការកែតម្រូវដោយសួរបញ្ជាក់អតិថិជនផ្តល់សម្ភាសន៍
- អ្នកសម្ភាសន៍ ត្រូវអានខ្លឹមសារដែលបង្ហាញពីការយល់ព្រមផ្តល់សម្ភាសន៍ឱ្យអតិថិជនផ្តល់សម្ភាសន៍បានស្តាប់លឺ និងយល់ពីខ្លឹមសារនៃការចូលរួមក្នុងដំណើរការនេះគឺជាការស្ម័គ្រចិត្ត។
- ពេលអានចប់ អ្នកសម្ភាសន៍ត្រូវសួរបញ្ជាក់ទៅអ្នកផ្តល់សម្ភាសន៍ ថាតើលោក លោកស្រីយល់ព្រមផ្តល់សម្ភាសន៍ដែរឬទេ?
  - ✓ មិនយល់ព្រម៖ អ្នកសម្ភាសន៍ត្រូវបញ្ចប់នីតិវិធីត្រឹមនេះ
  - ✓ យល់ព្រម៖ អ្នកសម្ភាសន៍ត្រូវបន្តការសម្ភាសន៍ និងបំពេញព័ត៌មានរហូតដល់ចប់
- អ្នកសម្ភាសន៍ ត្រូវឆែកមើលឡើងវិញ(និងធ្វើការកែតម្រូវបើមាន)នូវព័ត៌មានដែលបានបំពេញរួច និងបញ្ជូនមករក្សាទុកក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យ(វានឹងបង្ហាញប្រាប់ថា ករណី" **ថ្មី**" )សម្រាប់ការពិនិត្យផ្ទៀងផ្ទាត់ និងអនុម័ត។

# ដំហានទី៤៖ ការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ និងអនុម័ត

- មន្ត្រីពិនិត្យផ្ទៀងផ្ទាត់ ត្រូវប្រើប្រាស់គណនីចូលទៅក្នុងមុខងារ **ពិនិត្យផ្ទៀងផ្ទាត់ព័ត៌មាន** នៅក្នុងមូលដ្ឋានទិន្នន័យ (ករណី" **ថ្មី** " )
  - ✓ ពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ករណី " **ថ្មី** " → ករណី " **បានពិនិត្យរួច** "
  - ✓ មូលដ្ឋានទិន្នន័យនឹងបញ្ជូនករណី " **បានពិនិត្យរួច** " → មន្ត្រីអនុម័ត
- មន្ត្រីអនុម័ត ត្រូវប្រើប្រាស់គណនីចូលទៅក្នុងមុខងារ **អនុម័តព័ត៌មាន** ដែលបានពិនិត្យផ្ទៀងផ្ទាត់រួច នៅក្នុងមូលដ្ឋានទិន្នន័យ( ករណី " **បានពិនិត្យរួច** " )
  - ✓ អនុម័តទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ករណី" **បានពិនិត្យរួច** " → ករណី " **បដិសេដ** " ឬ " **ឯកភាព** "
  - ✓ មូលដ្ឋានទិន្នន័យនឹងបញ្ជូន៖
    - ➢ ករណី " **បដិសេធន៍** " → មន្ត្រីពិនិត្យផ្ទៀតផ្ទាត់ដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានសារឡើងវិញ និងបញ្ជូនទៅមន្ត្រីអនុម័តសារជាថ្មី
    - ➢ ករណី " **ឯកភាព** " → មន្ត្រីពិនិត្យផ្ទៀតផ្ទាត់ដើម្បីផលិត/បោះពុម្ពបណ្ណសមធម៌។

# ដំហានទី៥៖ ការបោះពុម្ព និងការផ្តល់បណ្ណសមធម៌

- ប្រព័ន្ធមូលដ្ឋានទិន្នន័យក្រសួងផែនការ នឹងផលិតបណ្ណសមធម៌
- មន្ត្រីពិនិត្យផ្ទៀងផ្ទាត់ អាចបោះពុម្ព
- មន្ត្រីអនុម័តចុះហត្ថលេខា និងបោះត្រា ដើម្បីចែកជូនដល់អតិថិជន

បណ្ណសមធម៌ដែលចេញដោយគ្លីនិកART មិនមានកាលបរិច្ឆេទផុតសុពលភាពឡើយ។

# ៣.២. ដំណើរការផ្តល់បណ្ណសមធម៌ និង ដំណើរការដកបណ្ណសមធម៌ (២)

- ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ ត្រូវធ្វើបច្ចុប្បន្នកម្មជាប្រចាំត្រីមាស
- អ្នកសម្ភាសន៍ ត្រូវពិនិត្យផ្ទៀងផ្ទាត់បណ្ណសមធម៌ដូចមានបរិយាយក្នុងជំហានទី១
- អតិថិជនដែលមកទទួលសេវាសុខភាពនៅគ្លីនីកART អាចប្រើប្រាស់បណ្ណសមធម៌ជាលក្ខណៈបុគ្គលដែលចេញដោយគ្លីនីកART ឬបណ្ណសមធម៌ជាលក្ខណៈគ្រួសារដែលចេញដោយក្រុមប្រឹក្សាឃុំ សង្កាត់
  → មិនអាចកាន់បណ្ណទាំងពីរ
- ត្រូវតែដកបណ្ណសមធម៌ជាលក្ខណៈបុគ្គលចេញពីអតិថិជនជាសមាជិកគ្រួសារក្រីក្រកម្រិត១ ឬកម្រិត២
- អ្នកមានចំណែកពាក់ព័ន្ធ នឹងកិច្ចដំណើរការនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ មានសិទ្ធិស្នើសុំដកបណ្ណសមធម៌ជាលក្ខណៈបុគ្គលដែលចេញដោយគ្លីនិកART បាន។

# ៣.៣. ការតាមដានត្រួតពិនិត្យ និងការគ្រប់គ្រងមតិជំទាស់និងសំណូមពរ

ការតាមដានត្រួតពិនិត្យ និងការដោះស្រាយមតិជំទាស់ និងសំណូមពរ ត្រូវប្រើប្រាស់យន្តការដែលមានស្រាប់របស់ក្រសួងផែនការ។

# ៣.៤. រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច

- ក្រសួងផែនការ
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
- អ្នកមានចំណែកពាក់ព័ន្ធដទៃទៀត


idpoor.gov.kh fb.com/IDPoor Cambodia https://t.me/idpoorcambodia 023 726 814 youtube.com/IDPoor Cambodia

# ក្រសួងផែនការ

- ❑ រៀបចំសេចក្តីណែនាំ និងសម្របសម្រួលដល់កិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
- ❑ កៀរគរធនធានសម្រាប់គាំទ្រដល់កិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
- ❑ រៀបចំឯកសារ និងសម្ភារបណ្តុះបណ្តាល និងសម្ភារផ្សព្វផ្សាយការយល់ដឹងដល់អ្នកមានចំណែកពាក់ព័ន្ធ
- ❑ ផ្តល់ការបណ្តុះបណ្តាលដល់ក្រុមការងារ និងអ្នកមានចំណែកពាក់ព័ន្ធ
- ❑ រៀបចំ ប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ថ្នាក់ជាតិ និងផ្តល់ទិន្នន័យតាមរយៈ APIដល់ស្ថាប័នពាក់ព័ន្ធ និងដៃគូផ្តល់សេវានានាតាមការស្នើសុំដោយធានាការការពារនិងរក្សាការសំងាត់ទិន្នន័យ
- ❑ សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធដែលធ្វើការងារផ្នែកគាំពារសង្គម និងជំនួយនានា
- ❑ តាមដានត្រួតពិនិត្យ និងរៀបចំរបាយការណ៍ការអនុវត្តកិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
- ❑ ផ្តល់ការណែនាំដល់មន្ទីរផែនការរាជធានី ខេត្ត ក្នុងការចុះជួយគាំទ្រការអនុវត្តរបស់មន្ត្រីបង្គោលទទួលបន្ទុកការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ក្នុងដែនរាជធានី ខេត្តរបស់ខ្លួន។។

# អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

- ផ្តល់ការណែនាំគោលនយោបាយ និងការសម្របសម្រួលទូទៅសម្រាប់កិច្ចគាំពារសង្គមសម្រាប់អ្នកផ្ទុកមេរោគអេដស៍
- កៀរគរធនធានសម្រាប់គាំទ្រដល់កិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
- ទទួល និងប្រើប្រាស់ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍
- សហការ និងសម្របសម្រួលជាមួយអ្នកមានចំណែកពាក់ព័ន្ធដើម្បីធានាថាអ្នកផ្ទុកមេរោគអេដស៍ទទួលបានប័ណ្ណសមធម៌
- ស្វែងរក និងពិគ្រោះយោបល់ជាមួយអ្នកមានចំណែកពាក់ព័ន្ធដើម្បីផ្តល់ជំនួយសង្គមដល់អ្នកផ្ទុកមេរោគអេដស៍
- ចូលរួមតាមដានត្រួតពិនិត្យតាមដានកិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
- គាំទ្រការលើកកំពស់ការយល់ដឹងដល់អ្នកមានចំណែកពាក់ព័ន្ធ
- ត្រូវរក្សាការសំងាត់ទិន្នន័យអត្តសញ្ញាណបុគ្គលដែលបានពីការប្រមូលទិន្នន័យតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍។

# មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ(១)

- ដឹកនាំ សហការ គាំទ្របច្ចេកទេសសម្រាប់ដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍នៅគ្លីនីកART
- សហការ និងសម្របសម្រួលជាមួយក្រសួងផែនការរៀបចំសកម្មភាពពង្រឹងសមត្ថភាពដល់មន្ត្រីបង្គោលចុះឈ្មោះអ្នកផ្ទុកនៅតាមគ្លីនីកART(អំពីកិច្ចដំណើរការចុះឈ្មោះ អំពីការប្រើប្រាស់កម្មវិធីសម្រាប់ចុះឈ្មោះ និងការត្រួតពិនិត្យគុណភាពព័ត៌មានដែលបានកត់ត្រា)
- ធានាថាអតិថិជនគ្លីនីកART ដែលគ្មានប័ណ្ណសមធម៌ បានចុះឈ្មោះដោយស្ម័គ្រចិត្តដើម្បីទទួលបានបណ្ណសមធម៌
- ជម្រុញដល់ប្រធានគ្លីនីកARTទាំងអស់ត្រូវយកចិត្តទុកដាក់ដល់អតិថិជនបានចុះឈ្មោះតាមការស្ម័គ្រចិត្ត
- ផ្តល់បរិក្ខារ និងសម្ភារ(ដូចជា កុំព្យូទ័រ ព្រីនធើ និងទឹកថ្នាំកូល័រ ក្រដាសបោះពុម្ពប័ណ្ណសមធម៌)ដល់គ្លីនីកART
- តាមដានត្រួតពិនិត្យកិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ និងចែករំលែកអំពីបញ្ហាដែលកើតមាន និងរកដំណោះស្រាយផ្សេងៗជាមួយក្រុមការងារ
- រៀបចំ និងគ្រប់គ្រងបញ្ជីឈ្មោះមន្ត្រីបង្គោលចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ បង្កើតគណនីអ្នកប្រើប្រាស់ចូលទៅមុខងាររបស់ខ្លួន។ មន្ត្រីបង្គោលចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ មានសមាសភាពដូចខាងក្រោម៖

# មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ(២)

- អ្នកសម្ភាសន៍
  - ✓ ពិនិត្យផ្ទៀងផ្ទាត់ប័ណ្ណសមធម៌នៅក្នុងមូលដ្ឋានទិន្នន័យក្រសួងផែនការអំពីស្ថានភាពផ្ទុកមេរោគអេដស៍របស់សមាជិកគ្រួសារ និងធ្វើបច្ចុប្បន្នកម្មព័ត៌មាននៅក្នុងមូលដ្ឋានទិន្នន័យគ្លីនីកART
  - ✓ ផ្តល់ប្រឹក្សា និងពន្យល់ណែនាំដល់អតិថិជនដែលមកទទួលសេវាសុខភាពនៅគ្លីនិកART អំពីដំណើរការ និងអត្ថប្រយោជន៍នៃការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
  - ✓ ពន្យល់ពីការរក្សាការសំងាត់នូវទិន្នន័យដែលបានប្រមូលតាមរយៈនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
  - ✓ ពន្យល់អំពីសិទ្ធរបស់អតិថិជន ក្នុងការចូលរួមដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
  - ✓ បញ្ជូនឈ្មោះអតិថិជន (ករណី " ថ្មី")ដែលបានសម្ភាសន៍រួចទៅមន្ត្រីផ្ទៀងផ្ទាត់

# មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ(៣)

- មន្ត្រីផ្ទៀងផ្ទាត់
  - ✓ ផ្ទៀងផ្ទាត់ទិន្នន័យដែលទទួលបានពីការសម្ភាសន៍(បញ្ជីឈ្មោះអតិថិជនដែលបានសម្ភាសន៍ ករណី " ថ្មី ")
  - ✓ កែសម្រួលព័ត៌មាន ករណីរកឃើញមានចំណុចខុសឆ្គង
  - ✓ បញ្ជូន ឈ្មោះអតិថិជនដែលបានផ្ទៀងផ្ទាត់ទិន្នន័យរួច(ករណី " បានពិនិត្យរួច ") ទៅមន្ត្រីអនុម័ត
  - ✓ បោះពុម្ពបណ្ណសមធម៌ជូនអតិថិជន បន្ទាប់ពីទទួលបានការអនុម័តរួច
- មន្ត្រីអនុម័ត
  - ✓ ទទួល និងអនុម័តឈ្មោះអតិថិជន(ករណី " បានពិនិត្យរួច ")ដែលបានបញ្ជូនមកពីមន្ត្រីផ្ទៀងផ្ទាត់ទិន្នន័យ
  - ✓ បញ្ជូនឈ្មោះអតិថិជនដែលបានអនុម័តរួច(ករណី "ឯកភាព")ទៅមន្ត្រីផ្ទៀងផ្ទាត់ដើម្បីបោះពុម្ពបណ្ណសមធម៌
  - ✓ ចុះហត្ថលេខា និងបោះត្រាលើបណ្ណសមធម៌សម្រាប់ចែកជូនអតិថិជនរបស់ខ្លួន
  - ✓

# អ្នកមានចំណែកពាក់ព័ន្ធដទៃទៀត (១)

- ចែករំលែក និងចូលរួមបង្កើនការយល់ដឹងដល់ក្រុមគោលដៅអំពីកិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍
- ជួយសម្របសម្រួល និងផ្តល់ការគាំទ្រដល់ការងារពាក់ព័ន្ធនឹងការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍(ស្ម័គ្រចិត្តធ្វើជាមន្ត្រីបង្គោលចុះឈ្មោះតាមការស្នើសុំពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ)
- ផ្តល់ជាធនធានផ្សេងៗតាមការស្ម័គ្រចិត្តសម្រាប់កិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍(ការពង្រឹងសមត្ថភាព ការលើកកម្ពស់ការយល់ដឹងដល់ក្រុមគោលដៅ ការផ្តល់ឧបករណ៍ និងសម្ភារដល់គ្លីនិកសេវាART ។ល។)
- ស្នើសុំទិន្នន័យពីក្រសួងផែនការ ដើម្បីទទួលបាន និងប្រើប្រាស់ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍សម្រាប់ការផ្តល់សេវាសង្គម និងកិច្ចអន្តរាគមន៍នានាដោយធានារក្សាការសំងាត់បំផុត
- ពង្រឹង និងពង្រីកលទ្ធភាពផ្តល់សេវាគាំពារសង្គមចាំបាច់នានាបន្ថែមទៀតដល់អ្នកផ្ទុកមេរោគអេដស៍
- អាចចូលរួមតាមដានត្រួតពិនិត្យ និងរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកិច្ចដំណើរការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍។

# អ្នកមានចំណែកពាក់ព័ន្ធដទៃទៀត (២)

- អ្នកមានចំណែកពាក់ព័ន្ធដទៃទៀត មានជាអាទិ៍៖
  - ✓ អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិគាំពារសង្គម
  - ✓ ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល
  - ✓ តំណាងដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល(ជាតិ និងអន្តរជាតិ) សង្គមស៊ីវិល និងតំណាងសហគមន៍ដែលធ្វើការផ្តល់សេវាដល់អ្នកផ្ទុកមេរោគអេដស៍
  - ✓ អ្នកធ្វើកិច្ចការផ្តល់សេវាសង្គមដល់អ្នកផ្ទុកមេរោគអេដស៍
  - ✓ អ្នកដឹកនាំសាសនា
  - ✓ ... ។ល។

# ៣.៥. ការរក្សាការសំងាត់នៃទិន្នន័យអ្នកផ្ទុកមេរោគអេដស៍

- ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ ត្រូវបានរក្សាការពារត្រឹមត្រូវ និងត្រូវប្រើប្រាស់សម្រាប់គោលបំណងផ្តល់អន្តរាគមន៍សេវាសង្គមតែប៉ុណ្ណោះ
- មន្ត្រីបង្គោលចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ ត្រូវរក្សាការសំងាត់ទិន្នន័យដែលបានប្រមូល
- អ្នកប្រើប្រាស់ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍ ត្រូវធានារក្សាការពារទិន្នន័យទាំងនេះ និងធានាថាមិនចែកបន្តទៅភាគីទី៣ ដោយមិនមានការអនុញ្ញាតពីក្រសួងផែនការឡើយ។

# ៤. ជំហានបន្ទាប់

- ❑ បញ្ចប់ការរៀបចំ APP សម្រាប់ចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ និងធ្វើតេស្តសាកល្បង → សប្តាហ៍ទី៤ ខែវិច្ឆិកា
- ❑ ប្រកាសដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំស្តីពីនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ → សប្តាហ៍ទី៤ ខែវិច្ឆិកា
- ❑ បណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធអំពីនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍ → សប្តាហ៍ទី២ ខែធ្នូ
- ❑ សិក្ខាសាលាផ្សព្វផ្សាយស្តីពីការដាក់ឱ្យដំណើរការនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោដស៍ → សប្តាហ៍ទី៣ ខែធ្នូ
- ❑ ដំណើរការនីតិវិធីចុះឈ្មោះអ្នកផ្ទុកមេរោដស៍នៅតាមគ្លីនីក → សប្តាហ៍ទី១ ខែមករា ឆ្នាំ២០២៣

ក្រសួងផែនការ




ក្រសួងផែនការ

# សូមអរគុណ

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

idpoor.gov.kh

fb.com/IDPoor Cambodia

https://t.me/idpoorcambodia

youtube.com/IDPoor Cambodia

023 726 814